**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៦៩៤ សហវ

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## ការបង្កើត និងដាក់ឱ្យដំណើរការទីស្នាក់ការគយ និងរដ្ឋាករ ប្រចាំសន្និធិគយបណ្តោះអាសន្ន តេង ឡាយ អាហារណ៍ នីហារណ៍ និងដឹកជញ្ជូន (ទីស្នាក់ការគយ និងរដ្ឋាករ ផែស្ងួត តេង ឡាយ)

*** ៙ ***

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្តីជូនដំណឹងលេខ ១៩៤១ សជណ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខ ០០៨ សហវ.គរ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើតការិយាល័យគ្រប់គ្រងផែស្ងួត និងឃ្លាំងដែលគ្រប់គ្រងដោយគយ និងទីលានបញ្ចេញទំនិញពីគយ និងរដ្ឋាករ
- បានឃើញប្រកាសលេខ ១០៦ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីសន្និធិគយបណ្តោះអាសន្ន

- យោងកិច្ចសន្យាស្តីពីការបង្កើត និងធ្វើអាជីវកម្មសន្និធិគយបណ្តោះអាសន្ន (ផែស្ងួត) សំរាប់បញ្ចេញទំនិញពីគយ និងរដ្ឋាករ រវាងទីចាត់ការគយ និងរដ្ឋាករ និងក្រុមហ៊ុន តេង ឡាយ អាហារ៍ណ នីហារ៍ណ និងដឹកជញ្ជូន ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៨
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១:** បង្កើត និងដាក់ឱ្យដំណើរការនូវទីស្នាក់ការគយ និងរដ្ឋាករផែស្ងួត តេង ឡាយ ដែលស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ការិយាល័យគយ និងរដ្ឋាករផែស្ងួត នៃទីចាត់ការគយ និងរដ្ឋាករ។

**ប្រការ ២:** ទីស្នាក់ការគយ និងរដ្ឋាករផែស្ងួត តេង ឡាយ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ ៣:** ទីស្នាក់ការគយ និងរដ្ឋាករផែស្ងួត តេង ឡាយ មានភារកិច្ចដូចតទៅ ÷

- គ្រប់គ្រង និងត្រួតពិនិត្យទំនិញក្នុងទីតាំងសន្និធិគយបណ្តោះអាសន្ន លើគ្រប់ទំនិញនាំចេញក្រៅក្របខ័ណ្ឌវិនិយោគ និងទំនិញនាំចូលគ្រប់ប្រភេទ លើកលែងតែមានការអនុញ្ញាតដោយឡែកពីទីចាត់ការគយ និងរដ្ឋាករ។
- ចាត់តាំងក្រុមអនុរក្ស និងក្រុមត្រួតពិនិត្យលើកិច្ចប្រតិបត្តិការគ្រប់គ្រងទំនិញនាំចេញ នាំចូលដែលស្ថិតនៅក្នុងសន្និធិគយបណ្តោះអាសន្ន តេង ឡាយ លើទំនិញដូចចែងខាងលើ។
- ត្រួតពិនិត្យ និងប្រមូលពន្ធចំពោះមុខទំនិញនាំចូល នាំចេញដូចចែងខាងលើ និងអនុញ្ញាតឱ្យទំនិញចេញពីសន្និធិគយបណ្តោះអាសន្ន ក្រោយពីការត្រួតពិនិត្យ និងបញ្ចប់បែបបទគយតាមបទបញ្ញត្តិច្បាប់ជាធរមាន។

**ប្រការ ៤:** ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥:** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

គាត ឈន់

**ចម្លងជូន :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- ឯកសារ- កាលប្បវត្តិ